# កញ្ចប់ជំនួយបានប្រើប្រាស់ពេលបញ្ចុះ

MCCSA
Multicultural Communities Council of South Australia

Get an Emergency Kit together today! It may save your life in an emergency.

**រកប្រដាប់ប្រដាសម្រាប់គ្រាអាសន្នដាក់ជាមួយគ្នានៅថ្ងៃនេះ! វាអាចសង្គ្រោះជីវិតអ្នកនៅពេលមានគ្រោះអាសន្ន។**

ប្រដាប់ប្រដាសម្រាប់គ្រាអាសន្នអាចជួយកុំឲ្យខាតពេលដែលមានតម្លៃក្នុងគ្រាមានអាសន្ន។

វាធ្វើឲ្យមានវត្ថុដែលអ្នកអាចត្រូវការប្រសិនបើអ្នកដាច់ភ្លើង ឬក៏អ្នកត្រូវការចាកចេញពីផ្ទះដោយប្រញាប់។

ប្រដាប់ប្រដាសម្រាប់គ្រាអាសន្នរបស់អ្នកគួរមាន ៖

- វិទ្យុប្រើថ្មដោយមានថ្មបំរុងផង
- ពិលដោយមានថ្មបំរុងផង
- គ្រឿងពេទ្យសង្គ្រោះបន្ទាន់
- ទៀននិងឈើគូសដែលមិនអាចសើមទឹក។ ឯកសារសំខាន់ៗរួមទាំងលេខទូរសព្ទសម្រាប់គ្រាអាសន្ន
- ផែនការគ្រាអាសន្នសម្រាប់ផ្ទះរបស់អ្នកមួយច្បាប់
- ថង់មិនអាចសើមទឹកសម្រាប់ដាក់វត្ថុដែលមានតម្លៃ

ចូរដាក់ប្រដាប់ប្រដាសម្រាប់គ្រាអាសន្នរបស់អ្នកក្នុងប្រអប់ឬថង់មិនអាចសើមទឹក។

នៅពេលអ្នកសម្រេចចិត្តថាចាកចេញ សូមថែមគ្រឿងទាំងនេះ ៖

- ទូរសព្ទចល័តនិងឧបករណ៍បញ្ចូលភ្លើង
- វេជ្ជបញ្ជា ឱសថ សម្ភារៈបង្គន់
- ខោអាវនិងស្បែកជើងដែលមាំ
- អាហារមិនងាយខូច និងទឹកពិសា
- អ្វីៗពិសេសដែលអ្នកត្រូវការសម្រាប់សមាជិកឯទៀតក្នុងគ្រួសារ
  ប្រសិនបើអ្នកមានសត្វចិញ្ចឹម សូមកុំភ្លេចខ្សែចង អាហារ និងចាន។

បញ្ជីសម្រាប់ផ្ទៀងរបស់ SASES មាននៅ www.ses.sa.gov.au *ក្រោម About us/Resources*

*សេវាអគ្គីភ័យជនបទ មានប្រដាប់ប្រដានិងឯកសារព័ត៌មានស្រដៀងហ្នឹងដែរ។*

*សូមចូលមើលគេហទំព័ររបស់ពួកគេដើម្បីរកមើលប្រដាប់ប្រដាអ្វីថែមទៀតដែលគេតម្រូវចាំបាច់ឲ្យមានក្នុងខណៈមានអគ្គីភ័យ - **ប្រដាប់ប្រដាសម្រាប់គ្រាអាសន្នមុនរដូវអគ្គីភ័យរបស់ CFS និង ព័ត៌មានអំពីប្រដាប់ប្រដាសម្រាប់គ្រាអាសន្នរបស់ CFS នៅ*** https://www.cfs.sa.gov.au

នៅពេលបង្កើតបានរួចហើយ ចូរដាក់បញ្ជីផ្ទៀងផ្ទាត់អំពីប្រដាប់ប្រដាសម្រាប់គ្រាអាសន្នរបស់អ្នកនៅលើទូទឹកកក ហើយប្រើវាដើម្បីរំលឹកអ្នកឲ្យផ្ទៀងផ្ទាត់/បំពាក់ឡើងវិញសម្ភារៈដែលបាត់ឬខ្វះ។

សារនេះផ្តល់ជូនលោកអ្នកដោយ Multicultural Communities Council of South Australia
ជាផ្នែកមួយនៃគំរោងកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ ឧបត្ថមថវិកាដោយរដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី
និងរដ្ឋាភិបាលនៃរដ្ឋអូស្ត្រាលីខាងត្បូង។

Multicultural Communities Council of South Australia
113 Gilbert Street, Adelaide SA 5000
**PHONE** (08) 8345 5266
**E** mccsa@mccsa.org.au
**www.mccsa.org.au**